| |
|---|
| តុលាការខេត្ត |
| សៀមរាប-ឧត្តរមានជ័យ |
| សាលក្រម |
| លេខ ៣៦ ខ ចុះថ្ងៃទី ០៨ |
| ខែ ឧសភា ឆ្នាំ ២០០៦ |
| សំណុំរឿងរដ្ឋប្បវេណី |
| លេខ ៤៩៧ ចុះថ្ងៃទី ១៤ |
| ខែ ធ្នូ ឆ្នាំ ២០០៥ |

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## គោរពនាមប្រជារាស្ត្រខ្មែរ
## តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី នៃរដ្ឋកម្ពុជា ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ។

បានបើកសវនាការជាសាធារណៈ នៅនាទីតុលាការខេត្តសៀមរាប-ឧត្តរមានជ័យ នៅថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០០៦ ដោយមានសមាសភាពដូចតទៅ :

**ចៅក្រមជំនុំជំរះ**

លោក [redacted] ប្រធានតុលាការខេត្ត

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមតុលាការ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

សាលក្រមនេះចូលជាស្ថាពរ ចាប់ពីថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០០៦
ដោយពុំមានភាគីណាចូលមកប្តឹងទាស់ ឬប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។
សៀមរាប . ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០០៦
ក្រឡាបញ្ជី
ហត្ថលេខា និងត្រា
[redacted]

ដើម្បីជំនុំជំរះរឿងក្តីរដ្ឋប្បវេណីលេខ ៤៩៧ ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៥ ដែលមានកម្មវត្ថុបណ្តឹង : **ប្តឹងសុំលែងលះប្តី, សុំសិទ្ធិគ្រប់គ្រងកូន និង សុំគ្រប់គ្រងទ្រព្យសម្បត្តិរួម ។**

រវាងដើមចោទឈ្មោះ **ឧ ចន** អាយុ ៣៦ឆ្នាំ ជាតិខ្មែរ របររកស៊ី លក់ដូរ ទីលំនៅសព្វថ្ងៃនៅភូមិវិហារចិន ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប ឪពុកឈ្មោះ **ឧ បឈ** ( រ) ម្តាយឈ្មោះ **ឋ សរ** (រ) ប្តីឈ្មោះ **ឈ គ** មានកូន ០៣នាក់ ។

និងចុងចម្លើយឈ្មោះ **ឈ គ** អាយុ ៣៥ឆ្នាំ ជាតិខ្មែរ របររកស៊ី គ្រូបង្រៀន ទីលំនៅសព្វថ្ងៃនៅភូមិវិហារចិន ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប ឪពុកឈ្មោះ **ឈ ឃ** (រ) ម្តាយឈ្មោះ **ឋ ត** (រ) ប្រពន្ធឈ្មោះ **ឧ ចន** មានកូន ០៦ នាក់ ។

**ឯរឿងហេតុមានដូចតទៅ :**

តាមពាក្យបណ្តឹងចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០០៥ របស់ដើមចោទឈ្មោះ **ឧ ចន** ថា កាលពីខែ ឧសភា ឆ្នាំ ១៩៩២ ខ្លួន និង ឈ្មោះ **ឈ គ** បានគ្នាជាប្តីប្រពន្ធតាមច្បាប់មានកូន ០៣នាក់ ។ ការរស់នៅជាប្តី ប្រពន្ធមិនចុះសំរុងនឹងគ្នា ពេលខ្លួនមានជម្ងឺ ប្តីខ្លួនមិនជួយមើលថែរក្សាខ្លួនមិនជួយរកស៊ីចិញ្ចឹមកូន និង ប្រច័ណ្ឌខ្លួនទៅនឹងអ្នកដទៃ ដោយគ្មានហេតុផល ទើបបណ្តាលអោយខ្លួនអស់មនោសញ្ចេតនាពីប្តី ។

**នាពេលសវនាការ**

ដើមចោទឈ្មោះ ឆ ចន បានឆ្លើយថា ខ្លួនប្ដឹងសុំលែងលះប្ដី សុំសិទ្ធិគ្រប់គ្រងកូន និង សុំសិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិដោយមូលហេតុថា កាលពីខែ ឧសភា ឆ្នាំ ១៩៩២ ខ្លួន នឹងឈ្មោះ ឈ គ បានគ្នាជាប្ដីប្រពន្ធតាមច្បាប់ មានកូន ០៣នាក់ ។ ការរស់នៅជាប្ដីប្រពន្ធមិនចុះសំរុងគ្នា ពេលខ្លួនមានជម្ងឺ ប្ដីខ្លួនមិនជួយមើលថែរក្សាខ្លួនមិនជួយរកស៊ីចិញ្ចឹមកូន និង ប្រច័ណ្ឌខ្លួនទៅនឹងអ្នកដទៃ ដោយគ្មានមូលហេតុទើបបណ្ដាលអោយខ្លួនអស់មនោសញ្ចេតនាពីប្ដី ។ ខ្លួនសុំសិទ្ធិគ្រប់គ្រងកូនទាំង ០៣នាក់ គឺកូនទី១ ឈ្មោះ ឃ ទឧ ភេទប្រុស អាយុ ១២ឆ្នាំ កូនទី២ ឈ្មោះ ឃ ទធ ភេទប្រុស អាយុ ០៨ឆ្នាំ និងកូនទី៣ ឈ្មោះ ឃ ហច ភេទស្រី អាយុ ០៥ឆ្នាំ ដោយខ្លួនមិនទាមទារប្រាក់អាហារកិច្ចចិញ្ចឹមកូនទេ ។ ចំណែកទ្រព្យសម្បត្តិរួមមានរថយន្ត ០១គ្រឿង ម៉ាកស៊ើប ពណ៌ខ្មៅ ម៉ូតូ ០១ គ្រឿងម៉ាកហុងដា ពណ៌ខ្មៅ ស៊េរីឆ្នាំ ២០០៤, ដីមួយប្លង់ទំហំ ២.៨២៩ម៉ែត្រក្រឡា ស្ថិតនៅភូមិត្រពាំងត្រែង ឃុំសាលាកំរើក, ដីមួយប្លង់ទំហំ ១២ម x ៣០ម មានផ្ទះតូចមួយខ្នង ស្ថិតនៅភូមិវិហារចិន ឃុំស្វាយដង្គំ . ដីមួយប្លង់ទំហំ ៥៣៤ម៉ែត្រក្រឡា (ដីទិញក្រុមហ៊ុនគ្នា) ស្ថិតនៅភូមិបឹងដូនប៉ា ឃុំស្លក្រាម. ដីមួយប្លង់ទំហំ ៦១១ម៉ែត្រក្រឡា ស្ថិតនៅភូមិទ្រៀក ឃុំសៀមរាប និង ដីមួយប្លង់ទំហំ ១.៨៦៥ម៉ែត្រក្រឡា ស្ថិតនៅភូមិគ្រួស ឃុំស្វាយដង្គំ ខ្លួនសុំសិទ្ធិគ្រប់គ្រងជាកម្មសិទ្ធិ ដោយខ្លួនសុខចិត្តប្រគល់ប្រាក់ចំនួន ២០.០០០ដុល្លា (ម្ភៃពាន់ដុល្លា) ទៅប្ដី ។ ថា ប្រាក់នេះខ្លួនបានប្រគល់អោយប្ដីរួចរាល់ហើយ ។

ក្រឡាបញ្ជីអានចម្លើយចុងចម្លើយឈ្មោះ ឈ គ បានឆ្លើយថា ខ្លួនយល់ព្រមលែងលះប្រពន្ធខ្លួនដែរ ដោយមូលហេតុថា ការរស់នៅមិនចុះសំរុងគ្នា ប្រពន្ធខ្លួនមិនគោរពខ្លួនជាប្ដី ហើយទៅណាមកណាមិនដែលប្រាប់ខ្លួនជាប្ដី ដើររកស៊ីតែជាមួយនឹងមនុស្សប្រុស ។ កូនទាំង ០៣នាក់គឺ កូនទី១ ឈ្មោះ ឃ ទឧ ភេទប្រុស អាយុ ១២ឆ្នាំ កូនទី២ ឈ្មោះ ឃ ទធ ភេទប្រុស អាយុ ០៨ឆ្នាំ និង កូនទី៣ ឈ្មោះ ឃ ហច ភេទស្រី អាយុ ០៥ឆ្នាំ ខ្លួនប្រគល់អោយដើមចោទគ្រប់គ្រង ។ ចំណែកទ្រព្យសម្បត្តិរួមមានរថយន្ត ០១គ្រឿង ម៉ាកស៊ើប ពណ៌ខ្មៅ ម៉ូតូ ០១គ្រឿង ម៉ាកហុងដា ពណ៌ខ្មៅ ស៊េរីឆ្នាំ ២០០៤, ដីមួយប្លង់ទំហំ ២.៨២៩ម៉ែត្រក្រឡា ស្ថិតនៅភូមិត្រពាំងត្រែង ឃុំសាលាកំរើក, ដីមួយប្លង់ទំហំ ៥៣៤ម៉ែត្រក្រឡា (ដីទិញក្រុមហ៊ុនគ្នា) ស្ថិតនៅភូមិបឹងដូនប៉ា ឃុំស្លក្រាម. ដីមួយប្លង់ទំហំ ៦១១ម៉ែត្រក្រឡា ស្ថិតនៅភូមិទ្រៀក ឃុំសៀមរាប និង ដីមួយប្លង់ទំហំ ១.៨៦៥ម៉ែត្រក្រឡាស្ថិតនៅភូមិគ្រួស ឃុំស្វាយដង្គំ ខ្លួនសុខចិត្តប្រគល់អោយដើមចោទគ្រប់គ្រងជាកម្មសិទ្ធិ ពីព្រោះខ្លួនបានទទួលប្រាក់ចំនួន ២០.០០០ដុល្លា (ម្ភៃពាន់ដុល្លា) ពីដើមចោទរួចរាល់ហើយ ដោយខ្លួនមិនទាមទារទ្រព្យសម្បត្តិរួមអ្វីទាំងអស់ ។

តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថា ឆ្លងតាមសវនាការនេះ គោលដៅអាពាហ៍ពិពាហ៍លែងបានសំរេចស្ថានភាពប្ដីប្រពន្ធមានភាពធ្ងន់ធ្ងរ ភាគីទាំងពីរពុំអាចរួមរស់នៅជាមួយគ្នាតទៅទៀតបានឡើយ ដោយដើមចោទ និង ចុងចម្លើយអស់មនោសញ្ចេតនាពីគ្នា ។

ហេតុនេះសុំតុលាការពិចារណាសំរេចតាមច្បាប់ចុះ ។

-បានស្ដាប់ដើមចោទឆ្លើយអោយការណ៍ និង ប្ដឹងសុំ

-បានស្ដាប់សេចក្ដីដោះសាររបស់ចុងចម្លើយ

-បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ

**តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ**

ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## យល់ឃើញថា

-ពាក្យបណ្តឹងចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០០៥ របស់ដើមចោទមានលក្ខណៈត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

-គូស្វាមីភរិយានេះ បានក្លាជាប្តីប្រពន្ធមានចំណងអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ ។

-ដើមចោទ ប្តឹងសុំលែងលះចុងចម្លើយ ហើយចុងចម្លើយបានព្រមព្រៀងដែរនោះ មានលក្ខណៈត្រឹមត្រូវ តាមច្បាប់ ។

-ដើមចោទប្តឹងសុំសិទ្ធិគ្រប់គ្រងកូន ០៣នាក់ គឺកូនទី១ ឈ្មោះ ឃ ទឧ ភេទប្រុស អាយុ ១២ឆ្នាំ កូនទី២ ឈ្មោះ ឃ ទធ ភេទប្រុស អាយុ ០៨ឆ្នាំ និងកូនទី៣ ឈ្មោះ ឃ ឣច ភេទស្រី អាយុ ០៥ឆ្នាំ ហើយ ចុងចម្លើយបានព្រមព្រៀងដែរនោះមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

-ដើមចោទមិនប្តឹងទាមទារប្រាក់អាហារកិច្ចចិញ្ចឹមកូន តុលាការនឹងពិចារណាសំរេចតាមច្បាប់ ។

-ដើមចោទសុំសិទ្ធិគ្រប់គ្រងរថយន្ត ០១គ្រឿង ម៉ាកស៊ើប ពណ៌ខ្មៅ ម៉ូតូ ០១គ្រឿង ម៉ាកហុងដា ពណ៌ខ្មៅ ស៊េរីឆ្នាំ ២០០៤, ដីមួយប្លង់ទំហំ ២,៨២៥ម៉ែត្រក្រឡាស្ថិតនៅភូមិត្រពាំងត្រែង ឃុំសាលាកំរើក, ដី មួយប្លង់ទំហំ ១២ម x ៣០ម មានផ្ទះតូចមួយខ្នង ស្ថិតនៅភូមិវិហារចិន ឃុំស្វាយដង្គំ, ដីមួយប្លង់ទំហំ ៥៣៤ម៉ែត្រក្រឡា( ដីទិញក្រុមហ៊ុនគ្នា) ស្ថិតនៅភូមិបឹងដូនប៉ា ឃុំស្លក្រាម, ដីមួយប្លង់ទំហំ ៦១១ម៉ែត្រ ក្រឡា ស្ថិតនៅភូមិទ្រៀក ឃុំសៀមរាប និង ដីមួយប្លង់ទំហំ ១,៨៦៥ម៉ែត្រក្រឡាស្ថិតនៅភូមិគ្រួស ឃុំស្វាយដង្គំ ហើយសុខចិត្តប្រគល់ប្រាក់ចំនួន ២០.០០០ដុល្លា( ម្ភៃពាន់ដុល្លា) ទៅចុងចម្លើយ ដោយចុង ចម្លើយព្រមព្រៀងដែរនោះ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

-គោលដៅនៃអាពាហ៍ពិពាហ៍ពុំអាចបានសំរេចឡើយ ដោយដើមចោទ និង ចុងចម្លើយអស់មនោសញ្ចេតនា ពីគ្នា ។

## ហេតុដូច្នេះ
## វិនិច្ឆ័យសេចក្តី

១-ទទួលពាក្យបណ្តឹងរបស់ដើមចោទ ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២-សំរេចអោយឈ្មោះ ឱ ចឧ និងឈ្មោះ ឈ គ លែងលះគ្នាចាប់ពីថ្ងៃនេះតទៅ តាមការព្រមព្រៀង របស់គូភាគី ។

៣-អោយឈ្មោះ ឱ ចឧ ស្ថិតនៅភាពមេម៉ាយចំនួន ៣០០ថ្ងៃ គិតចាប់ពីថ្ងៃនេះតទៅ ។

៤-កូន ០៣នាក់គឺ កូនទី១ ឈ្មោះ ឃ ទឧ ភេទប្រុស អាយុ ១២ឆ្នាំ កូនទី២ ឈ្មោះ ឃ ទធ ភេទ ប្រុស អាយុ ០៨ឆ្នាំ និងកូនទី៣ ឈ្មោះ ឃ ឣច ភេទស្រី អាយុ ០៥ឆ្នាំ ត្រូវប្រគល់អោយឈ្មោះ ឱ ចឧ គ្រប់គ្រងតាមការព្រមព្រៀងរបស់គូភាគី ។ តែអោយឈ្មោះ ឈ គ ជួយចិញ្ចឹមកូនទាំង ០៣នាក់ តាមលទ្ធភាពដែលខ្លួនមាន ។

មាតាបិតាត្រូវមានសិទ្ធិ និងករណីយកិច្ចអប់រំ ថែរក្សា ចិញ្ចឹមកូនតាមមាត្រា ៧៤ នៃច្បាប់អាពាហ៍ ពិពាហ៍ និងគ្រួសារ ។

៥-ទុកសិទ្ធិអោយចុងចម្លើយទៅសួរសុខទុក្ខដល់កូនបាន ។

៦-ទ្រព្យសម្បត្តិរួម រថយន្ត ០១គ្រឿង ម៉ាកស៊េប ពណ៌ខ្មៅ ម៉ូតូ ០១គ្រឿង ម៉ាកហុងដា ពណ៌ខ្មៅ ស៊េរី ឆ្នាំ ២០០៤, ដីមួយប្លង់ទំហំ ២,៨២៥ម៉ែត្រក្រឡាមានលិខិតចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០០៤ ស្ថិតនៅភូមិត្រពាំងត្រែង ឃុំសាលាកំរើក, ដីមួយប្លង់ទំហំ ១២ម x ២៥ម មានផ្ទះតូចមួយខ្នងមានលិខិតផ្ទេរសិទ្ធិកាន់កាប់ដី ចុះថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០០៣ ស្ថិតនៅភូមិវិហារចិន ឃុំស្វាយដង្គំ, ដីមួយប្លង់ទំហំ ៥៣៤ម៉ែត្រក្រឡា (ដីទិញក្រុមហ៊ុនគុា) មានលិខិតផ្ទេរសិទ្ធិកាន់កាប់ដី ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្ថិតនៅភូមិបឹងដូនប៉ា ឃុំស្លក្រាម, ដីមួយប្លង់ទំហំ ៥៦៥ម៉ែត្រក្រឡាមានលិខិតផ្ទេរសិទ្ធិកាន់កាប់ដី ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០៤ ស្ថិតនៅភូមិទ្រៀក ឃុំសៀមរាប និង ដីមួយប្លង់ទំហំ ១,៨៤៩,៩៣ ម៉ែត្រក្រឡា មានលិខិតផ្ទេរសិទ្ធិកាន់កាប់ដី ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០០២ ស្ថិតនៅភូមិគ្រួស ឃុំស្វាយដង្គំ ត្រូវប្រគល់អោយឈ្មោះ ឧ ចន គ្រប់គ្រងជាកម្មសិទ្ធិ ។ ប៉ុន្តែអោយឈ្មោះ ឧ ចន ប្រគល់ប្រាក់ចំនួន ២០,០០០ដុល្លា (ម្ភៃពាន់ដុល្លា) ទៅឈ្មោះ ឈ គ តាមការព្រមព្រៀងរបស់គូភាគី ។

៧-សំរេចអោយចុងចម្លើយបង់ប្រាក់ប្រដាប់ក្តីគឺ ពន្ធចុះបញ្ជីក្តី និង ពន្ធហ្លឹង ១,៨០០រ,០០ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន ២០០រ,០០ រង្វាន់អ្នកប្រគល់ដីកាកោះ ៥,០០០រ,០០ បូករួម ៧,០០០រ,០០ ។ ប្រាក់នេះបានកាត់យកពីប្រាក់ ៧,០០០រ,០០ ដែលដើមចោទបានបង់ទុករួចហើយ ។ កាលបើហួសឧទ្ធរណ៍ត្រូវបង្គាប់អោយចុងចម្លើយសងប្រាក់ ៧,០០០រ,០០ នេះទៅដើមចោទវិញ ។

៨-សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយ ។ បើកផ្លូវប្តឹងទាស់ និង ឧទ្ធរណ៍តាមច្បាប់កំណត់ ។

**ក្រឡាបញ្ជីសវនាការ** [redacted]

**ចៅក្រមជំនុំជំរះ** [redacted]